ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សំណុំរឿងរដ្ឋប្បវេណីលេខ ១៦៣
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

សាលក្រមលេខៈ ១៧ "ក"
ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពត

- បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅសាលសវនាការ ។
- កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ ២០២១។
- កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ។

## ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តកំពត

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

**ដើមចោទ៖** ឈ្មោះ [redacted] រ៉ាំ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

-មានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយ៖** ឈ្មោះ [redacted] ខៃ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

-មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

## អង្គហេតុ និងចំណុចទទាស:

**១. ការទាមទាររបស់ដើមចោទ៖**

- សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ខៃ

**២. ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

**២.១. អំពីដំណើររឿង**

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៧ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយមកទល់និងបច្ចុប្បន្ន គឺអស់រយៈពេលប្រហែល ១៣ឆ្នាំហើយ ទំនាស់កើតមានជាបន្តបន្ទាប់ ទើបតែប្រហែល ២ទៅ៣ខែ នេះមានទំនាស់ដែលពុំអាចរស់នៅជាមួយគ្នាបាន។ ចុងចម្លើយបានគៀបសង្កត់ដើមចោទគ្រប់បែបយ៉ាង គ្មានសិទ្ធិក្នុងការរស់នៅជាមួយគ្នា ហើយចុងចម្លើយពុំដែលរាប់រកឪពុកម្តាយ នឹងបងប្អូនខាងដើមចោទទេ នៅពេលដឹងថាកូនមកលេងផ្ទះឪពុកម្តាយដើមចោទម្តងៗ ចុងចម្លើយវាយធ្វើបាបកូនដោយគ្មានការយោគយល់ មូលហេតុទាំងអស់នេះហើយទើបដើមចោទប្តឹងសុំលែង។ ការរស់នៅជាមួយគ្នានេះ ដើមចោទ និងចុងចម្លើយមានកូន ០១នាក់ ឈ្មោះ [redacted] សុខណា ភេទស្រី អាយុ១២ឆ្នាំ និងទ្រព្យសម្បត្តិរួមទាំងអស់មាន៖ ផ្ទះគ្រឿងឈើពីរខ្នងផ្ទាល់ ទទឹង៥,៥០ ម៉ែត្រ បណ្តោយ ៧ ម៉ែត្រ, ដីភូមិមួយកន្លែង ៣៣ម៉ែត្រ x ៣២ម៉ែត្រ, ម៉ូតូឌុប៥០ មួយគ្រឿង, ឧបករណ៍



Scanned with CamScanner

តន្ត្រីសម័យ រួមទាំងឡានដឹក២,៥ តោនមួយគ្រឿង។ ទ្រព្យទាំងអស់នេះទុកឱ្យកូន និងចុងចម្លើយជាអ្នកគ្រប់គ្រង ចំណែកឯបំណុលធនាគារ នឹងជំពាក់ ឯកជនទាំងអស់ ទុកឱ្យចុងចម្លើយជាអ្នកសង។ ចំណែកឯដើមចោទសុំយកឡាន ATOZ មួយគ្រឿង នឹងឧបករណ៍ផ្សារដែក ព្រមទាំងសងប្រាក់ជំពាក់បងធម៌នៅខេត្តបាត់ដំបងចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក។

**២.២.ការអះអាងរបស់ភាគី**

**+មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖** នាងខ្ញុំមិនមានអ្វីថ្លែងការបន្តទេ សុំឱ្យតុលាការ សម្រេចតាមការទាមទាររបស់កូនក្តីរបស់នាងខ្ញុំ

**+មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖** ចំពោះការទាមទារលែងលះរបស់ដើមចោទកូនក្តីរបស់នាងខ្ញុំ សុំឱ្យដើមចោទទៅលោះប្លង់ដីដែលដើមចោទបានយកទៅដាក់បញ្ចាំតាមគំនិតផ្តើមរបស់ខ្លួន។

**+ ឈ្មោះ** [redacted] **សុខណា ភេទស្រី អាយុ១២ឆ្នាំ បានធ្វើសេចក្តីថ្លែងការណ៍ថា៖** នាងខ្ញុំសុំរស់នៅជាមួយនឹងម្តាយរបស់នាងខ្ញុំឈ្មោះ [redacted] ខែ។

**៣.ចំណុចវិវាទមាន៖**

- តើការទាមទារលែងលះរបស់ដើមចោទមានមូលហេតុស្របតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីដែរឬទេ?

**៤.ភស្តុតាង៖**

- កិច្ចសន្យាខ្ចីប្រាក់ (ឥណទានខ្នាតតូច) ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- កិច្ចសន្យាហ៊ីប៉ូតែករបស់ឈ្មោះ [redacted] វ៉ា ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤
- កិច្ចសន្យាហ៊ីប៉ូតែករបស់ឈ្មោះ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឈ្មោះ [redacted] បូ
- សំបុត្រអាពាហ៍ពិពាហ៍របស់ [redacted] វ៉ា និង ស៊ុន ខែ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១១
- សំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សុខណា។

## សំអាងហេតុ

ឆ្លងតាមលទ្ធផលសាកសួរ និងពិនិត្យភស្តុតាងនៅទីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១.តាមសំបុត្រអាពាហ៍ពិពាហ៍របស់ [redacted] វ៉ា និង ស៊ុន ខែ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១១ កំណត់បានថា ដើមចោទឈ្មោះ [redacted] វ៉ា និងចុងចម្លើយឈ្មោះ [redacted] ខែ មានចំណងអាពាហ៍ពិពាហ៍ដែលមានអានុភាពស្របតាមមាត្រា ៩៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។ ហេតុនេះតុលាការមានសមត្ថកិច្ច និងមូលដ្ឋាន ដើម្បីយកមកពិនិត្យ និងសម្រេច។

២. ដើមចោទឈ្មោះ [redacted] វ៉ា បានទាមទារលែងលះពីចុងចម្លើយឈ្មោះ [redacted] ខែ ដោយយកមូលហេតុ រស់នៅមិនចុះសម្រុងដែលធ្វើឱ្យមិនអាចរស់នៅជាមួយគ្នាបាន ព្រមទាំងចុងចម្លើយពុំដែលរាប់រកឪពុកម្តាយ និងបងប្អូនខាងគ្រួសារខ្លួន។ តុលាការ យល់ឃើញថា ការណ៍លើកយកមូលហេតុនេះមានបញ្ញត្តិ នៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ហើយចុងចម្លើយក៏ឯកភាពក្នុងការលែងលះគ្នាដែរ។ នាំឱ្យតុលាការកំណត់បានថា ដើមចោទ និងចុងចម្លើយពិតជាអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន។

៣. តាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សុខណា កំណត់បានថាដើមចោទឈ្មោះ [redacted] វ៉ា និងចុងចម្លើយឈ្មោះ [redacted] ខែ ពិតជាឪពុកម្តាយប្រាកដមែន។

៤. គូភាគីបានសម្រេចឯកភាពគ្នាប្រគល់សិទ្ធិឱ្យកូនរបស់ខ្លួនឈ្មោះ [redacted] សុខណា ជាអ្នកសម្រេចក្នុងការជ្រើសរើសថាតើ ចង់រស់នៅជាមួយដើមចោទ ឬចុងចម្លើយ? ក្រោយមកនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឈ្មោះ [redacted] សុខណា ក៏បានឆ្លើយប្រាប់មកកាន់តុលាការថា ខ្លួនសុំរស់នៅជាមួយនឹងចុងចម្លើយ។ ម្យ៉ាងទោះបីនៅក្នុងកម្មវត្ថុនៃការទាមទារមិនបានកំណត់អំពីបន្ទុកលើសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនក៏ដោយ ក៏ច្បាប់បើសិទ្ធិឱ្យតុលាការ



Scanned with CamScanner

សម្រេចដោយឆន្ទានុសិទ្ធិ ស្របតាមមាត្រា១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៥. ការទាមទាររបស់ចុងចម្លើយមិនមានលក្ខណៈត្រឹមត្រូវនោះទេ ព្រោះថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ គឺចុងចម្លើយបានថ្លែងការណ៍ថា ខ្លួនព្រមលែងលះជាមួយដើមចោទ តែត្រូវឱ្យដើមចោទប្រគល់ប្រាក់ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ជាថ្លៃលែងលះ ដោយមិនចាំបាច់បង់អាហាកាតព្វកិច្ចលើការចិញ្ចឹមកូនមកឱ្យខ្លួននោះទេ ប៉ុន្តែនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយបែរជាទាមទារឱ្យដើមចោទទៅលោះប្លង់ដីដែលដើមចោទយកទៅបញ្ចាំទៅវិញ ដែលនេះវាផ្ទុយទៅនឹងការទាមទាររបស់ដើមចោទដែលធ្វើជាលាយល័ក្ខអក្សរ ដែលជាកម្មវត្ថុនៃចំណុចវិវាទទៅវិញ ដែលមើលទៅវាគ្មានលក្ខណៈច្បាស់លាស់ទាល់តែសោះ។

៦. ចំពោះបំណុលគឺជាទ្រព្យសម្បត្តិអកម្ម ដែលមិនអាចឱ្យតុលាការសម្រេចបាននោះទេ ផ្ទុយមកវិញតុលាការទុកសិទ្ធិឱ្យភាគីធ្វើការតទល់គ្នា ក្នុងករណីដែលមានបណ្តឹងទាមទារមកកាន់តុលាការ។ ប៉ុន្តែដោយមានការបារម្ភថាភាគីណាមួយមិនសហការអនុវត្តកាតព្វកិច្ចក្រោយពីការលែងលះ គប្បីតុលាការសម្រេចលើបញ្ហានេះ។

៧. ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

**១** - ទទួលស្គាល់ការទាមទារលែងលះរបស់ដើមចោទឈ្មោះ [redacted] វាំ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ ពីចុងចម្លើយឈ្មោះ [redacted] ខែ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ។

**២** - កំណត់ឱ្យឈ្មោះ [redacted] ខែ ភេទស្រី អាយុ៤១ឆ្នាំ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុខណា ភេទស្រី អាយុ១២ឆ្នាំ។ អ្នកដែលពុំមានអំណាចមេបាក្រោយពេលលែងលះជាមួយគ្នាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ហើយអ្នកដែលមានអំណាចមេបាត្រូវជួយសម្រួលឱ្យបានល្អលើបញ្ហានេះ។

**៣** - បង្គាប់ឱ្យឈ្មោះ [redacted] វាំ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ បង់អាហារកាតព្វកិច្ចចំពោះកូន ចំនួន ២០០,០០០ (ម្ភៃម៉ឺន)រៀល ក្នុងមួយខែ ឱ្យចុងចម្លើយឈ្មោះ [redacted] ខែ ដែលជាអ្នកមានអំណាចមេបា រហូតដល់កូនមាននីតិភាព ដោយបង់នៅសប្តាហ៍ទីមួយ ជារៀងរាល់ដើមខែនីមួយៗ គិតចាប់ពីថ្ងៃចេញសាលក្រមនេះ។

**៤** - ដើមចោទឈ្មោះ [redacted] វាំ និងចុងចម្លើយឈ្មោះ [redacted] ខែ ទោះបីជាលែងលះជាមួយគ្នា និងបញ្ចប់ទំនាក់ទំនងជាប្តីប្រពន្ធក៏ដោយ ក៏កាតព្វកិច្ចនៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ របស់គូភាគីនៅតែមានរហូតដល់អនុវត្តចប់កិច្ចសន្យា។

**៥** - ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-សាលក្រមនេះ ភាគីអាចប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៤កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកំពត, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner